# បទល្មើសព្រហ្មទណ្ឌ៖ ធាតុផ្សំសម្ភារៈ (*Actus Reus*) និងការខកខាន (Omission)

១. ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌមានអត្តនោម័ត និងសម្ភារៈ។ ធាតុផ្សំសម្ភារៈ សំដៅលើសកម្មភាពមិនល្អ (bad act)។ ក្នុងន័យដើម វាសំដៅដល់ចលនារាងកាយ បង្កើតចេញជាសកម្មភាព (physical movement)។ ឧទាហរណ៍ សកម្មភាពចាប់យកវត្ថុ មកគ្រប់គ្រងជារបស់ខ្លួន (បទចោរកម្មជាដើម)។ ទោះបីជាយ៉ាងនេះក្តី សកម្មភាពរាងកាយមួយចំនួន មានឥទ្ធិពលមកពីកត្តាខាងក្រៅ បើកឡានបុកគេ (ហូបថ្នាំពេទ្យ ធ្វើឲ្យងងុយដេក ក្នុងអំឡុងពេលបើកបរ) ជ្រុះវត្ថុពីដៃ ធ្វើឲ្យគ្រោះថ្នាក់អ្នកជិតខ្លួន (សាច់ដុំកន្ត្រាក់ដោយសារជំងឺ)។ សកម្មភាពខ្លះ ជម្រុញមកពីការបង្ខំ (បញ្ជាឲ្យបាញ់កាំភ្លើង) ហើយខ្លះទៀត ខុសឆ្គងនឹងសីលធម៌ តែមិនខុសនឹងច្បាប់ (សម្លាប់មនុស្ស ជាការអនុវត្តទោសប្រហារជីវិត)។ សកម្មភាពខ្លះ ត្រូវបានធ្វើរួមគ្នា។ ទង្វើខកខានខ្លះ អាចត្រូវបានចាត់ថាជាអំពើ (ដូចជាការខកខានមិនបានបង់ពន្ធ)។ ការកាន់កាប់វត្ថុខុសច្បាប់ ត្រូវបានចាត់ថាជាសកម្មភាព។ បទល្មើសខ្លះ ទាមទារនូវសកម្មភាព ដូចជាប្រភេទបទល្មើសទាមទារនូវទង្វើ (conduct offense)។ បទល្មើសទទួលខុសត្រូវតឹងរឹង (Strict Liability Offense) តម្រូវឲ្យមានសកម្មភាពជាឆន្ទៈ ឬស្ម័គ្រចិត្ត (voluntary act) http://www.measboralaws.com/detail/1048។

២. សកម្មភាព តម្រូវឲ្យមានឆន្ទៈ ។ បុគ្គលម្នាក់ មានចេតនាបើកបរ ទោះបីដឹងថាខ្លួនគាត់នឿយហត់។ ក្រោយមក គាត់បាត់បង់ស្មារតី បង្កគ្រោះថ្នាក់ (Involuntary Act) យុត្តិសាស្ត្រនឹងយកសកម្មភាពដោយឆន្ទៈដំបូង ជាធាតុផ្សំសម្ភារៈ។ នេះអនុលោមតាមទ្រឹស្តី ដែលថាជនល្មើសជាអ្នកបង្កើតស្ថានភាពដោយខ្លួនឯង ដែលអាចមានហានីយភ័យ ដែលគាត់ត្រូវបង្កា ឬបញ្ឈប់ (ក្នុងករណីនេះ កុំបើកបរ)។

៣. សកម្មភាព ខុសគ្នានឹង ការខកខាន (omission) ដែលជាការមិនបានបំពេញការងារអ្វីមួយដែលតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិ។ ទោះបីជាយ៉ាងនេះក្តី ច្បាប់មិនបានចែងទូលាយ នូវការខកខាន ដែលចាត់ថាជាធាតុផ្សំសម្ភារៈនៃបទល្មើសទេ ដោយសារ វាអាចនាំឲ្យមានការបំពារបំពានដល់គោលការណ៍សេរីភាព ឬស្វ័យភាពបុគ្គល (private autonomy)។ ការខកខាន ត្រូវបានប្រើ ក្នុងទំនាក់ទំនងពិសេស រវាងឪពុកម្តាយ និងកូន ក្នុងវិស័យវេជ្ជជីវៈ ដូចជាពេទ្យ និងវិស័យមួយចំនួនសំខាន់ចាំបាច់។ កាតព្វកិច្ចនេះមានប្រភពចេញពីកិច្ចសន្យា ឬការទទួលខុសត្រូវរដ្ឋប្បវេណី ដូចនេះ ការចាត់ការខកខាន ចូលក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវពិចារណាអំពីភាពសមស្រប ក្នុងការធ្វើដូចនេះ (reasonable imposition)។

៤. ក្រៅពីករណីខាងលើ ការដាក់ការទទួលខុសត្រូវ ដល់សាធារណជន ចំពោះការខកខាន តុលាការនឹងពិចារណា ថា តើជនល្មើសមានលទ្ធភាព ឬសមត្ថភាពក្នុងការបំពេញការងារ ដូចជាជួយសង្គ្រោះអ្នកលង់ទឹក ដែលមិននាំឲ្យគាត់មានហានីយភ័យដល់ជីវិតផ្ទាល់ខ្លួន ហើយជនរងគ្រោះពិតជាស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដែរឬទេ?។ ការមិនកម្រិត នឹងនាំឲ្យមនុស្សជាច្រើនទទួលខុសត្រូវព្រហ្មទណ្ឌ ហើយរដ្ឋនឹងទំនងជាមិនមានគុកគ្រប់គ្រាន់សម្រាប់ដាក់ជនល្មើសឡើយ។ សម្រាប់ការអនុវត្ត វាមានការលំ

បាកក្នុងការបង្ហាញជាតុអត្តនោម័តនៃការខកខាន ដែលនាំឲ្យមានផលវិបាកនៃទង្វើល្មើស។ រដ្ឋអាជ្ញាមានឆន្ទានុសិទ្ធិចោទប្រកាន់ ឬមិនចោទប្រកាន់ ហើយតុលាការអាចនឹងដាក់ទោសស្រាល។

**<u>កំណត់សំគាល់</u>៖** បទប្បញ្ញត្តិនៃច្បាប់កម្ពុជា ក៏បានចែងនូវកាតព្វកិច្ចមួយចំនួន ដែលការខកខាននឹងនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ មាត្រា៤៧ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ចែងថា៖ *មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ*។ http://www.measboralaws.com/detail/1049 ទាក់ទងនឹងមាត្រានេះ ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ មាត្រា ៣៣៧ បានចែង ដាក់ទោសពន្ធនាគារ និងពិន័យ ដល់ជនគ្រប់រូប ដែលមានអំណាចទៅលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ ដែលបង្អត់អាហារ ឬគ្មានការថែទាំរហូតដល់ខូចសុខភាពអនីតិជននោះ។ មាត្រា ៥៣០ នៃក្រមដដែល ដាក់ទោសពន្ធនាគារពី ១ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ ដល់បុគ្គលណាមិនប្ដឹងបរិហារ ពីការធ្វើបាបអនីតិជន ដែលខ្លួនបានដឹង។ ពាក់ព័ន្ធនឹងការខកខាន មាត្រា ៤ នៃក្រមឆ្នាំ ២០០៩ នេះ ចែងជាទូទៅថា៖ ...*ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែសឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។*http://www.measboralaws.com/detail/270

**<u>ឯកសារយោង</u>៖ 1.** Michael S. Moore, *Actus Reus* in Joshua Dressler, Encyclopedia of Crime and Justice, 2002, pp. 15-24; 2. Liu Daqun, *Actus Reus* in Antonio Cassese, the Oxford Companion to the International Criminal Justice, 2009, pp. 229-230; 3. Richard G. Singer and John Q. La Fond, Criminal Law: Example & Explanation, 2007, pp. 37-51; 4. Catherine Elliott and Frances Quinn, Criminal Law, 2006, pp.9-10.